*សេចក្តីប្រកាសព័ត៌មាន*

# របាយការណ៍ថ្មីគូសបញ្ជាក់អំពីវិធានការរួម ដើម្បីការពារកុមារពីហានិភ័យសុខភាពបរិស្ថាននៅកម្ពុជា

**រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤** – ដោយមានការគាំទ្រពីយូនីសេហ្វ ក្រសួងសុខាភិបាល បានចេញផ្សាយរបាយការណ៍ស្តីពីសុខភាពកុមារ និងបរិស្ថាន ដែលជារបាយការណ៍ដំបូងពាក់ព័ន្ធនឹងបញ្ហាសុខភាពកុមារ និងបរិស្ថាននៅកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងនេះមានការចូលរួមពីជាង ២៩ ក្រសួង និងមន្ទីរនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

របាយការណ៍ សុខភាពកុមារ និងបរិស្ថាន ដែលអនុវត្តដោយក្រសួងសុខាភិបាល ដោយមានការគាំទ្រពីយូនីសេហ្វ និងការរួមចំណែកពីមូលនិធិ Clarios ផ្តល់នូវទិដ្ឋភាពទូទៅគ្រប់ជ្រុងជ្រោយអំពីស្ថានភាពបច្ចុប្បន្ននៃសុខភាពបរិស្ថានរបស់កុមារនៅកម្ពុជា។ របាយការណ៍នេះគូសបញ្ជាក់អំពីហានិភ័យសុខភាពបរិស្ថានចម្បងៗ ដែលកុមារប្រឈម រួមមាន ការប្រឈមមុខនឹងការបំពុលខ្យល់ ការបំពុលទឹក និងចំណីអាហារ ភាពតានតឹងដោយសារកម្តៅ សារធាតុលោហៈពុល ថ្នាំសម្លាប់សត្វល្អិត និងសំណល់គ្រោះថ្នាក់ផ្សេងទៀត ហើយការប្រែប្រួលអាកាសធាតុបានធ្វើឲ្យបញ្ហាទាំងនេះមានលក្ខណៈកាន់តែមានធ្ងន់ធ្ងរបន្ថែមទៀត ។

លោកវេជ្ជបណ្ឌិត កុល ហៀវ ប្រ**ធាននាយកដ្ឋានការពារសុខភាព**នៃក្រសួងសុខាភិបាល បានឱ្យដឹងថា “ការធានានូវវឌ្ឍនភាពជាបន្តបន្ទាប់ចំពោះសុខភាពមាតា និងកុមារ គឺជាអាទិភាពចំបងរបស់រាជរដ្ឋាភិបាលកម្ពុជា។ យើងទទួលស្គាល់ថា ការគំរាមកំហែងផ្នែកសុខភាពបរិស្ថាន បង្កហានិភ័យគួរឱ្យកត់សម្គាល់ចំពោះសមិទ្ធផល ដែលយើងបានធ្វើទៅលើការពង្រឹងសុខភាពមាតា និងកុមារ នៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងទៅ។ “យើងមានការប្តេជ្ញាចិត្តយ៉ាងជ្រាលជ្រៅចំពោះការអនុវត្តគោលនយោបាយ និងកម្មវិធីពហុវិស័យ ដែលការពារសមិទ្ធផលទាំងនេះ។ ថ្ងៃនេះយើងមានមោទកភាពចំពោះការផ្សព្វផ្សាយរបាយការណ៍ជាស្ថាពរនៃការវាយតម្លៃថ្នាក់ជាតិស្តីពីសុខភាពបរិស្ថាន កុមារ និងបរិស្ថាន ដែលនឹងក្លាយជាមគ្គុទ្ទេសក៍នៃកិច្ចខិតខំប្រឹងប្រែងរបស់យើង។ តាមរយៈការដោះស្រាយគ្រោះថ្នាក់បរិស្ថាន យើងកំពុងកសាងអនាគតមួយ ដែលកាន់តែមានសុខភាពល្អ និងសុវត្ថិភាពសម្រាប់កុមារ និងមនុស្សជំនាន់ក្រោយរបស់យើង។”

ការប្រែប្រួលអាកាសធាតុ និងភាពរេចរឹលបរិស្ថានកំពុងគំរាមកំហែងក្នុងកម្រិតខុសៗគ្នាដល់ការរស់រានមានជីវិត សុខភាព ការអប់រំ ការការពារ និងសុខុមាលភាពរបស់កុមារ។ កំណើនជាសកលនៃជំងឺមហារីក ជំងឺទឹកនោមផ្អែម វិបត្តិពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធប្រសាទ និងជំងឺហឺត បានកើតឡើងដំណាលគ្នានឹងកំណើននៃការបំពុលខ្យល់ សំណល់អេឡិចត្រូនិក និងការប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់នៅក្នុងផលិតផលប្រចាំថ្ងៃ ដូចជា ប្លាស្ទិក ចំណីអាហារ គ្រឿងអេឡិចត្រូនិក របស់របរក្មេងលេង និងក្រែមរក្សាស្បែក ។

លោកបណ្ឌិត វីល ផាកស៍ នាយកយូនីសេហ្វប្រចាំកម្ពុជា បានមានប្រសាសន៍ឱ្យដឹងថា “បច្ចុប្បន្ន កុមារប្រឈមនឹងការគំរាមកំហែងផ្នែកបរិស្ថានជាច្រើនដែលមិនធ្លាប់មានពីមុនមក រួមមាន ការបំពុលខ្យល់ និងទឹក ភាពតានតឹងដោយសារកម្តៅ ព្រមទាំងការប្រឈមនឹងសំណល់ពុល និងសារធាតុបំពុល ដែលបង្កគ្រោះថ្នាក់ចំពោះសុខភាព និងការអភិវឌ្ឍខួរក្បាលរបស់កុមារ”។ “ភាពតក់ស្លុតនៅឆាកជីវិតដំបូងរបស់កុមារ ប៉ះពាល់ដល់សក្តានុពលរបស់

ពួកគេក្នុងការក្លាយជាអ្នកដឹកនាំ និងអ្នករួមចំណែកចំពោះសេដ្ឋកិច្ចរបស់ពួកគេនៅពេលអនាគត។ ការដោះស្រាយបញ្ហាស្មុគស្មាញទាំងនេះ ទាមទារឱ្យមានកិច្ចសហប្រតិបត្តិការពហុវិស័យ និងភាពជាដៃគូដ៏រឹងមាំ។ តាមរយៈការរួមសហការគ្នា យើងអាចបង្កើតបរិយាកាសកាន់តែមានសុខភាពល្អ ដើម្បីឱ្យកុមារគ្រប់រូបអាចធំលូតលាស់ និងសម្រេចបានសក្តានុពលពេញលេញរបស់ពួកគេ។ អនាគតរបស់ពួកគេ គឺពឹងផ្អែកលើការដោះស្រាយនេះហើយ។”

យូនីសេហ្វប៉ាន់ប្រមាណថា កុមារចំនួន ៣០០លាននាក់នៅទូទាំងសកលលោក រស់នៅក្នុងតំបន់ជាច្រើន ដែលខ្យល់ពុលមានកម្រិតខ្ពស់ជាងគោលការណ៍ណែនាំអន្តរជាតិចំនួនប្រាំមួយដង។ ដោយផ្អែកលើការប៉ាន់ប្រមាណជាសកលនេះ[1] កម្ពុជាស្ថិតនៅក្នុងចំណោមបណ្តាប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ ដែលប្រឈមមុខខ្ពស់បំផុតនឹងហានិភ័យបរិស្ថានចំនួនបី នោះគឺ ការបំពុលនៅក្នុងបរិយាកាសជុំវិញ ការបំពុលក្នុងអគារ និងការប៉ះពាល់នឹងសំណ។

នៅកម្ពុជា មានការប៉ាន់ប្រមាណថា កុមារជិតមួយនាក់ នៅក្នុងចំណោមប្រាំនាក់ ដែលមានអាយុក្រោមប្រាំឆ្នាំ បានទទួលមរណភាពដោយសារការបំពុលខ្យល់ទាំងនៅក្នុងអគារ និងទាំងនៅក្រៅអគារ ហើយកុមារអាយុក្រោម១៨ឆ្នាំជាង ៥០% មានកម្រិតសារធាតុសំណក្នុងឈាមខ្ពស់ ដោយសារការប៉ះពាល់នឹងសំណ។

ព័ត៌មានគួរឱ្យព្រួយបារម្ភនេះ គឺជាកាតាលីករចំពោះវិធានការរបស់រដ្ឋាភិបាលក្នុងការអនុវត្តការវាយតម្លៃសុខភាពកុមារ និងបរិស្ថាន ដែលត្រូវបានផ្សព្វផ្សាយនៅថ្ងៃនេះ។ អនុសាសន៍សំខាន់ៗពីរបាយការណ៍ សុខភាពកុមារ និងបរិស្ថាន រួមមាន៖ ការពង្រឹងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានទាំងនោះ ដើម្បីបង្ការ និងគ្រប់គ្រងការប៉ះពាល់នឹងសារធាតុពុល និងសារធាតុបង្ករោគ ការពង្រឹងសមត្ថភាពរបស់បុគ្គលិកសុខាភិបាលក្នុងការដោះស្រាយបញ្ហាសុខភាពបរិស្ថាន ការលើកកម្ពស់ការយល់ដឹង ការចូលរួមរបស់សហគមន៍ និងយុវជនក្នុងបញ្ហាបម្រែបម្រួលអាកាសធាតុ និងបរិស្ថាន ការអនុវត្តការស្រាវជ្រាវ និងការអង្កេតបន្ថែមទៀត ព្រមទាំងការពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងឃ្លាំមើលសុខភាពបរិស្ថាន។

ការវាយតម្លៃនេះបានជួយក្នុងការជំរុញវិធានការ និងភាពដៃជាដៃគូបន្ថែមទៀតនៅឆ្នាំនេះ ដូចជា ភាពជាដៃគូថ្មីរវាងយូនីសេហ្វ ទីភ្នាក់ងារជំនួយអាមេរិក USAID និងក្រសួងសុខាភិបាល ក្នុងការអនុវត្តការអង្កេតជាតិស្តីពី សុខភាពកុមារ និងបរិស្ថាន នៅក្នុងឆ្នាំ២០២៥ ដែលនឹងផ្តល់ទិន្នន័យកាន់តែច្បាស់អំពីវិសាលភាពនៃការបំពុលដោយលោហៈ រួមទាំងសំណ ចំពោះកុមារ និងស្ត្រីមានផ្ទៃពោះ និងប្រភពនៃការបំពុល។ បន្ថែមលើនេះ នៅឆ្នាំនេះ រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមនៅក្នុងកិច្ចសហការសកលពាក់ព័ន្ធនឹងសុខភាពកុមារ និងបរិស្ថាន និងភាពជាដៃគូសម្រាប់អនាគតមួយដែលគ្មានសំណ ដែលជាគំនិតផ្តួចផ្តើមសកល ក្រោមការដឹកនាំរបស់យូនីសេហ្វ និង USAID ដើម្បីប្រយុទ្ធប្រឆាំងនឹងការបំពុលដោយសំណចំពោះកុមារ ជាពិសេស នៅក្នុងប្រទេសមានចំណូលទាប និងមធ្យម។

###

---

[1] ការពិតអំពីការបំពុល៖ ការប្រឈមមុខរបស់កុមារចំពោះការបំពុលដោយសំណបង្កភាពអន្តរាយចំពោះការបង្កើតសក្តានុពលនៅពេលអនាគត យូនីសេហ្វ និង Pure Earth ខែកក្កដា ឆ្នាំ២០២០។

unicef for every child

អំពីយូនីសេហ្វ
យូនីសេហ្វធ្វើការងារនៅតាមទីកន្លែងលំបាកបំផុតមួយចំនួននៅក្នុងពិភពលោក ដើម្បីគាំទ្រដល់កុមារដែលស្ថិតក្នុងស្ថានភាពលំបាកបំផុត។នៅក្នុងប្រទេស និងដែនដីចំនួនជាង ១៩០ យើងធ្វើការងារដើម្បីកុមារគ្រប់រូបនៅគ្រប់ទីកន្លែង ដើម្បីកសាងពិភពលោកមួយកាន់តែល្អសម្រាប់មនុស្សគ្រប់រូប។ សម្រាប់ព័ត៌មានបន្ថែមអំពី យូនីសេហ្វ និងការងារនៅកម្ពុជា សូមចូលទៅកាន់៖ www.unicef.org.kh

សូមតាមដានយូនីសេហ្វប្រចាំកម្ពុជានៅលើ Facebook | Twitter | YouTube | Instagram | LinkedIn | Threads | TikTok

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

Hadrien Bonnaud
ប្រធានផ្នែកទំនាក់ទំនង យូនីសេហ្វប្រចាំកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣២៦០២០៤ អ៊ីម៉េល៖ hbonnaud@unicef.org

ចាន់ ទី
អ្នកឯកទេសផ្នែកទំនាក់ទំនង យូនីសេហ្វប្រចាំកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ២៦០ ២០៤ អ៊ីម៉េល៖ tchan@unicef.org